# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ ១០២៣.ព្រទ-៩៣

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ចៅក្រមជំនុំជម្រះក្តី និងស៊ើបសួរនៃតុលាការខេត្ត ក្រុង រាជធានី នៃព្រះរាជាណាចក្រកម្ពុជា**

*សូមជ្រាប។*

**កម្មវត្ថុ:** ការស៊ើបសួរចោទប្រកាន់ជាបទឧក្រិដ្ឋ ។

តាមបញ្ញាត្តិមាត្រា ៧៦ កថាខ័ណ្ឌទី ២ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី២៨-០១-១៩៩៣ ក្នុងបទឧក្រិដ្ឋកម្មនោះការស៊ើបសួរត្រូវតែមានមេធាវី ឬ អ្នកការពារចូលរួមដើម្បីការពារផលប្រយោជន៍មនុស្សត្រូវចោទ ។

ដូច្នេះការតែងតាំងអ្នកការពារ ឬមេធាវីត្រូវធ្វើការចាំបាច់។ ក៏ប៉ុន្តែនៅខេត្ត ក្រុង ខ្លះរីឯនៅរាជធានីភ្នំពេញ ក្នុងកាលៈទេសៈសព្វថ្ងៃមនុស្សត្រូវចោទពុំអាចរកអ្នកការពារ ឬមេធាវីណាម្នាក់ឲ្យការពារបានឡើយ ។ចំណែកតុលាការវិញក៏មិនមានលទ្ធភាពចាត់តាំងអ្នកការពារ ឬមេធាវីណាម្នាក់ឲ្យការពារមនុស្សត្រូវចោទបានដែរ ជាហេតុនាំឲ្យរាំងស្ទះដំណើរការនៃនីតិវិធីតុលាការផង និងខូចប្រយោជន៍ដល់មនុស្សត្រូវចោទផង ។

ដើម្បីជៀសវាង ឯការរាំងស្ទះនោះក្រសួងយល់ថា ចៅក្រមស៊ើបអង្កេតអាចបញ្ជូននូវ ដីកាចាត់តាំង ដូចមានគំរូផ្ញើជូនជាប់មកជាមួយនេះ ទៅអង្គការការពារសិទ្ធិមនុស្ស ឬ ទៅអ៊ិនតាក់ផ្នែកការពារសិទ្ធិមនុស្ស ដើម្បីចាត់អ្នកការពារម្នាក់ឲ្យមកបំពេញទម្រង់ទៅការពារមនុស្សត្រូវចោទបាន ។

នៅពេលម៉ោងកំណត់សួរចម្លើយ កាលណាមិនឃើញអ្នកការពារមនុស្សត្រូវចោទចូលមកបំពេញភារកិច្ចនេះទេ នោះចៅក្រមត្រូវធ្វើការកត់សម្គាល់ក្នុងកំណត់ហេតុសួរចម្លើយនូវអនុវត្តមាននេះរួចហើយធ្វើការស៊ើបសួរមនុស្សត្រូវចោទដោយគ្មានអ្នកការពារនេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៣

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ហេង វងុប៊ុនឆាត**